**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## សូមគោរពជូន

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៤៦ ឈានចូល ៤៧ ឆ្នាំ

***សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសមហាសិរីមង្គលដ៏ឧត្តុង្គឧត្តម ពោរពេញដោយក្តីសោមនស្សរីករាយ នៃពិធីចម្រើនជន្មាយុគម្រប់ ៤៦ ឈានចូល៤៧ ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមចូលរួមសម្តែងនូវសេចក្តីសោមនស្សរំភើបរីករាយក្រៃលែង និងសូមជូនសព្ទសាធុការពរជ័យសិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំមាតុភូមិកម្ពុជាមានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍកាន់តែរីកចម្រើនបន្តទៀត។

នាឱកាសដ៏មហាប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមោទនភាព និងក្តីអំណរសាទរយ៉ាងក្រៃលែង ដែលប្រទេសកម្ពុជាទទួលបានមេដឹកនាំបន្តវេនវ័យក្មេងដ៏ឈ្លាសវៃ និងប៉ិនប្រសព្វក្នុងការដឹកនាំនាវាកម្ពុជាមួយនេះឆ្ពោះទៅកាន់ការអភិវឌ្ឍលើគ្រប់វិស័យ និងបន្តរក្សានូវសន្តិភាព ដែលមិនអាចកាត់ថ្លៃបានឱ្យនៅស្ថិតស្ថេរគង់វង្សជាអមតៈ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ព្រមទាំងបុត្រាបុត្រី ជាទីស្រឡាញ់ សូមប្រកបដោយ សុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃ សុក្រ ៦កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ សីហា**